# គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា

# ការស្ទង់មតិសាធារណជន ឆ្នាំ២០១៦

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) បានដាក់ចេញនូវវិស័យគន្លឹះទាំង១៧ ដែលត្រូវចាត់ទុកជាបញ្ហាអាទិភាពក្នុង ការបង្កើតគោលនយោបាយនៅថ្នាក់អន្តរជាតិនិងជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រ ប្រយុទ្ធប្រឆាំងនឹងវិសមភាពនិងភាពអយុត្តិធម៌ និងដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ ត្រឹមឆ្នាំ២០៣០។

នៅប្រទេសកម្ពុជា អង្គការទស្សនៈពិភពលោកបានធ្វើការស្ទង់មតិថ្នាក់ជាតិមួយដើម្បីកំណត់ថា ក្នុងចំណោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង១៧ តើគោលដៅណាខ្លះ ដែលប្រជាពលរដ្ឋកម្ពុជាយល់ថាសំខាន់បំផុត សម្រាប់កំណត់ជាអាទិភាពក្នុងគោលនយោបាយ និងផែនការសកម្មភាពជាតិនានា ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សម្រាប់រយៈពេល១៥ឆ្នាំ ខាងមុខ។ ប្រជាពលរដ្ឋជាង១២០០០នាក់នៅទូទាំងប្រទេសកម្ពុជា បានចូលរួមក្នុងការស្ទង់មតិនេះ។

# អ្នកចូលរួមការស្ទង់មតិ




ប្រជាជន១២៦១៣នាក់
បានចូលរួមក្នុងការស្ទង់មតិ




ការស្ទង់មតិនេះធ្វើឡើងនៅក្នុង៩ខេត្តនិងក្រុង
គោលដៅរបស់អង្គការទស្សនៈពិភពលោក
( តំបន់ពណ៌ទឹកក្រូចលើផែនទី )




ជាកសិករឬអ្នកនេសាទ ៤៥.៦%

ជាសិស្សកម្រិតបឋមសិក្សារហូតដល់ឧត្តមសិក្សា ៣៤.២%

ជាមន្រ្តីរាជការ (ភាគច្រើនជាគ្រូបង្រៀន) បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ប្រជាពលរដ្ឋដែលប្រកបមុខរបរផ្ទាល់ខ្លួន ស្ត្រីមេផ្ទះ បុគ្គលិកវិស័យឯកជន កម្មកររោងចក្រកម្មករសំណង់និងកម្មករដទៃទៀត ១៦.៧%

មិនបានបញ្ជាក់ពីមុខរបររបស់ពួកគេឡើយ ៣.៥%

# តើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពណាខ្លះ ដែលប្រជាពលរដ្ឋកម្ពុជា យល់ថាគួរចាត់ទុកជាគោលដៅអាទិភាព ?

## លទ្ធផលសង្ខេបតាមលំដាប់នៃគោលដៅអាទិភាព




**SDG 1** ស្ដីពី **«គ្មានភាពក្រីក្រ៖** បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង» ទទួលបានការបោះឆ្នោតគាំទ្រច្រើនជាងគេបំផុតគឺ ៤៨.២% នៃអ្នកចូលរួមស្ទង់មតិទាំងអស់។

**SDG 16** ស្ដីពី **«សន្តិភាពនិងយុត្តិធម៌៖** លើកកម្ពស់សង្គមប្រកបដោយសន្តិភាពនិងបរិយាប័ន្ន សម្រាប់ការអភិវឌ្ឍដោយនិរន្តរភាព ផ្ដល់យុត្តិធម៌ដល់មនុស្សគ្រប់រូប និងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ននៅគ្រប់លំដាប់ថ្នាក់» ត្រូវបានចាត់ជាគោលដៅអាទិភាពទីពីរ ដោយមានអ្នកចូលរួមស្ទង់មតិ ៤៣.១% បានជ្រើសរើស។







**SDG 4** ស្ដីពី **«ការអប់រំដែលមានគុណភាព៖** ធានាឲ្យមានការអប់រំប្រកបដោយគុណភាពនិងសមធម៌ ព្រមទាំងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់មនុស្សគ្រប់រូប» ត្រូវបានជ្រើសជាគោលដៅអាទិភាពទី៣ ដោយមានការគាំទ្រចំនួន ៤២.៦% នៃអ្នកចូលរួមស្ទង់មតិទាំងអស់។

**SDG 3 & 6** គោលដៅដែលទទួលបានការគាំទ្រហើយស្ថិតនៅក្នុងលំដាប់ជាអាទិភាពទី៤និងទី៥ នោះគឺ SDG 3 (**សុខភាពល្អ និងសុខុមាលភាព**) ទទួលបាន ៣៤.៨% និង SDG 6 (**ទឹកស្អាតនិងអនាម័យ**) ទទួលបាន ៣២.៣%នៃអ្នកចូលរួមស្ទង់មតិទាំងអស់។






# អំពីប្រជាជនដែលបានជ្រើសរើសគោលដៅអាទិភាពទាំង៣

ប្រជាជន ៨៩% (ឬ១១២៣២នាក់) បានបោះឆ្នោតជ្រើសរើសគោលដៅយ៉ាងហោចណាស់១ ក្នុងចំណោម SDG 1 SDG 4 ឬ SDG 16 ដែលនេះបង្ហាញថាគោលដៅទាំងបីនេះ ពិតជាត្រូវបានឲ្យតម្លៃខ្ពស់ក្នុងចំណោមប្រជាជនភាគច្រើនក្នុងប្រទេសកម្ពុជា។

ក្រាហ្វិក៖ ប្រជាជនដែលជ្រើសរើសគោលដៅទាំង១៧




**ភេទ៖** ការចាត់អាទិភាពគោលដៅទាំង៣មានភាពខុសគ្នា ប្រសិនបើយើងបែងចែកតាមភេទរបស់អ្នកចូលរួមស្ទង់មតិ។ ស្ត្រីនិងកុមារីជ្រើសរើស SDG 1 យ៉ាងហោចណាស់ ១០% ច្រើនជាង SDG 16 និង SDG 4។ បុរសនិងកុមារាជ្រើសរើស SDG 16 មានចំនួនច្រើនជាងបន្តិចបន្តួចបើធៀបនឹងជម្រើសពួកគេលើ SDG 1 និងSDG 4។







**មុខរបរ៖** កសិករនិងអ្នកនេសាទ ស្ត្រីមេផ្ទះ និងកម្មករសំណង់បានជ្រើសរើស SDG 1 ច្រើនជាង SDG 4 និង SDG 16 ចំណែកឯមន្ត្រីរាជការ (ភាគច្រើនជាគ្រូបង្រៀន) និងប្រជាពលរដ្ឋដែលប្រកបមុខរបរផ្ទាល់ខ្លួន បានបោះឆ្នោតជ្រើសរើស SDG 4 ច្រើនជាងគោលដៅពីរផ្សេងទៀត។ សិស្សានុសិស្សនិងកម្មកររោងចក្របានបោះឆ្នោតចាត់អាទិភាពលើ SDG 16 ច្រើនបំផុត។






# តើអ្វីទៅជា SDGs?




១.**គ្មានភាពក្រីក្រ៖** បញ្ចប់គ្រប់ទម្រង់នៃភាពក្រីក្រនៅគ្រប់ទីកន្លែង

២.**គ្មានភាពអត់ឃ្លាន៖** បញ្ចប់នូវភាពអត់ឃ្លាន ទទួលបាននូវសន្តិសុខស្បៀង និងពង្រឹងអាហារូបត្ថម្ភ ព្រមទាំងលើកកម្ពស់ការធ្វើកសិកម្មដែលមានចីរភាព

៣.**សុខភាពល្អ៖** ធានាថាជីវិតរស់នៅប្រកបដោយសុខភាពល្អ និង លើកកម្ពស់សុខុមាលភាពរបស់ជនគ្រប់រូប ដោយមិនប្រកាន់អាយុ

៤. **គុណភាពនៃការអប់រំ៖** ធានាឲ្យមានគុណភាព និងសមភាពនៃការអប់រំ និងលើកកម្ពស់ឲ្យមានឱកាសសិក្សារៀនសូត្រឲ្យបានវែងឆ្ងាយសម្រាប់ជនគ្រប់រូប

៥. **សមភាពយេនឌ័រ៖** ទទួលឲ្យមានសមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី និងកុមារីទាំងអស់

៦.**ទឹកស្អាតនិងអនាម័យ៖** ធានាឲ្យមានទឹកស្អាតនិងអនាម័យ និងការគ្រប់គ្រងទឹកស្អាត និងអនាម័យ ដែលមានចីរភាពសម្រាប់ជនគ្រប់រូប

៧.**ថាមពលទំនើប៖** ធានាឲ្យមានការទទួលបាននូវថាមពលដែលទំនើប មានតម្លៃទាបអាចជឿជាក់បាន និងមានចីរភាពសម្រាប់ជនគ្រប់រូប

៨.**ការងារល្អ និងកំណើនសេដ្ឋកិច្ច៖** លើកកម្ពស់ឲ្យមានកំណើន សេដ្ឋកិច្ចដែលមាននិរន្តរភាព និងប្រកបដោយភាពមានការងារធ្វើនិងផលិតភាពពេញលេញព្រមទាំងការងារដែលសមរម្យសម្រាប់ជនគ្រប់រូប។

៩.**ការបង្កើតថ្មី និងហេដ្ឋារចនាសម្ព័ន្ធ៖** កសាងហេដ្ឋារចនាសម្ព័ន្ធដែលរឹងមាំ លើកកម្ពស់វិស័យឧស្សាហកម្ម និងជំរុញឲ្យមានការបង្កើតថ្មីសម្រាប់ជនគ្រប់រូប

១០.**កាត់បន្ថយវិសមភាព៖** កាត់បន្ថយភាពមិនស្មើគ្នា នៅក្នុងប្រទេស និងរវាងប្រទេសនិងប្រទេស

១១.**សហគមន៍ និងទីក្រុងដែលមាននិរន្តរភាព៖** ធ្វើឲ្យទីក្រុង និងទីកន្លែងស្នាក់នៅសម្រាប់ជនគ្រប់រូបមាន សុវត្ថិភាព បត់បែនតាមស្ថានភាព និងមានចីរភាព

១២.**ទំនួលខុសត្រូវចំពោះការប្រើប្រាស់ផលិតផល៖** ធានាឲ្យមាននិរន្តភាពនៃភាពអាចរកបាននូវផលិតផល និងគំរូផលិតភាព

១៣.**ការពារភពផែនដី៖** ធ្វើសកម្មភាពជាបន្ទាន់ក្នុងការលុបបំបាត់ បម្រែបម្រួលអាកាសធាតុនិងផលប៉ះពាល់របស់វា

១៤.**ជីវិតនៅក្រោមទឹក៖** អភិរក្ស និងប្រើប្រាស់មហាសមុទ្រ សមុទ្រ ជីវិតនិងធនធាននានាដែលនៅក្រោមទឹកឲ្យមាននិរន្តភាព ដើម្បីរក្សា ឲ្យមានការអភិវឌ្ឍដែលមានចីរភាព

១៥.**ជីវិតនៅលើទឹក៖** ការពារ បង្កើតឡើងវិញ និងលើកកម្ពស់ការ ប្រើប្រាស់ប្រព័ន្ធជីវៈចម្រុះនៃរាល់ជីវិតទាំងឡាយនៅលើដែនដីគោក ព្រមទាំងគ្រប់គ្រងឲ្យមាននិរន្តភាពព្រៃឈើ លុបបំបាត់ការកាប់បំផ្លាញព្រៃឈើ និងបញ្ឈប់ ហើយការពារថែរក្សាដីដែលបាត់ជីជាតិ និងបញ្ឈប់ នូវការបាត់បង់ជីវៈចម្រុះ

១៦.**សន្តិភាពនិងយុត្តិធម៌៖** លើកកម្ពស់ឲ្យមានសន្តិភាព និងសង្គម មួយដែលយកចិត្តទុកដាក់ចំពោះ ជនគ្រប់រូប ដើម្បីការអភិវឌ្ឍដែល មាននិរន្តភាព ហើយផ្តល់នូវការទទួលបាននូវភាពយុត្តិធម៌សម្រាប់ ជនគ្រប់រូប និងកសាងឲ្យមានស្ថាប័នផ្សេងៗដែលមានប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ នៅគ្រប់កម្រិតទាំងអស់សម្រាប់ជនគ្រប់រូប

១៧.**ភាពជាដៃគូសម្រាប់គោលដៅទាំងនេះ៖** ពង្រឹងមធ្យោបាយឬយន្តការសម្រាប់អនុវត្ត និងផ្តល់នូវកម្លាំងថាមពលជាថ្មីសម្រាប់ភាពជាដៃគូជាសកល ដើម្បីការអភិវឌ្ឍដែលមាននិរន្តរភាព

**ក្រុមអាយុ៖** កុមារ (អាយុ១៨ឆ្នាំឬក្មេងជាងនេះ) ក្រុមប្រជាជនដែលពេញកម្លាំងក្នុងការប្រកបការងារ (អាយុចន្លោះពី៣១ដល់ ៦០ឆ្នាំ) និងក្រុមមនុស្សចាស់ (អាយុពី៦០ឆ្នាំឡើងទៅ) បានជ្រើសរើស SDG 1 ជាអាទិភាព ច្រើនជាងរើសយក SDG 16 និង SDG 4។ យុវជន (អាយុចន្លោះពី១៥ដល់៣០ឆ្នាំ) ជ្រើសយក SDG 16 និង SDG 4 ច្រើនជាងបន្តិចបន្តួចបើធៀបនឹង SDG 1។



# អនុសាសន៍សំខាន់។

ខណៈដែលកម្ពុជាកំពុងធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព អង្គការទស្សនៈពិភពលោកជឿជាក់ថា លទ្ធផល នៃការស្ទង់មតិមួយនេះនឹងក្លាយជាភស្តុតាងដែលកើតមានទាន់ពេលវេលានិងមានអត្ថប្រយោជន៍មួយសម្រាប់ជាជំនួយក្នុងការចាត់អាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើតផែនការជាតិដែលធានាការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងចីរភាព។

តាមរយៈលទ្ធផលនៃការស្ទង់មតិនេះ អនុសាសន៍មួយចំនួនត្រូវបានស្នើឡើងសម្រាប់រាជរដ្ឋាភិបាលនិងភាគីដែលពាក់ព័ន្ធ៖

- សូមពិចារណាលើការចាត់អាទិភាពរបស់ប្រជាពលរដ្ឋ នៅពេលតាក់តែងផែនការ និងយុទ្ធសាស្រ្តថ្នាក់ជាតិផ្សេងៗ ជា ពិសេស ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ដើម្បីសម្រេចឲ្យបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់កម្ពុជា។
- ធានាឲ្យមានការសម្របសម្រួលល្អប្រសើរជាងមុន រវាងក្រសួងស្ថាប័ននិងអ្នកពាក់ព័ន្ធទាំងអស់ នៅក្នុងដំណើរការធ្វើមូលដ្ឋានីយកម្មលើ អាទិភាពនិងសូចនាកររបស់ SDGs នៅក្នុងផែនការសកម្មភាពនិងថវិកា ព្រមទាំងនៅក្នុងយន្តការសម្រាប់រាយការណ៍ និងធ្វើឲ្យមានគណនេយ្យភាព។
- លើកកម្ពស់ឲ្យមានការចូលរួមយ៉ាងទូលំទូលាយពីគ្រប់ភាគីក្នុងសង្គម រួមទាំងប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលនៅក្នុងដំណើរការធ្វើមូលដ្ឋានីយកម្ម SDGs នេះ និងធានាថាប្រជាពលរដ្ឋទាំងអស់ទទួលបាននូវការអប់រំផ្សព្វផ្សាយអំពី SDGs ដើម្បីឲ្យពួកគេអាចចូលរួមដោយពេញលេញក្នុងដំណើរការធ្វើមូលដ្ឋានីយកម្ម។
- ធ្វើឲ្យមានភាពប្រសើរឡើងលើការអនុវត្តគោលនយោបាយនិងយុទ្ធសាស្រ្តផ្សេងៗដែលរួមចំណែកធ្វើឲ្យសម្រេចបាននូវ SDG 1 ដើម្បីពន្លឿនការកាត់បន្ថយភាពក្រីក្រ។
- កំណត់ SDG 16 ជាអាទិភាពដើម្បីធានាឲ្យមានសន្តិភាព សុខសុវត្ថិភាពនិង សន្តិសុខតាមរយៈការពង្រឹងនូវយន្តការ ការការពារសង្គម នីតិរដ្ឋ ការលើកកម្ពស់សិទ្ធិមនុស្សនិងសេវាសង្គមនៅគ្រប់កម្រិតទាំងអស់ ដើម្បីការពារកុមារ ក៏ដូចជា ប្រជាជនគ្រប់រូប ពីការបៀតបៀន ការកេងប្រវ័ញ្ច ការជួញដូរ និងការរំលោភបំពានគ្រប់ទម្រង់ទាំងអស់។
- ដើម្បីសម្រេចបាន SDG 4 ត្រូវធានាឲ្យមានកម្មវិធីអប់រំរួមទាំងកម្មវិធីគាំពារ និងអភិវឌ្ឍន៍កុមារតូច ដែលប្រកបដោយគុណភាព និងមានលក្ខណៈបរិយាប័ន្ន តាមរយៈការធានាឲ្យមានបរិយាកាសរៀនសូត្រនិងសម្ភារៈបរិក្ខារដែលមនុស្សគ្រប់រូបអាចងាយរកបាន មានផាសុកភាព មេត្រីភាពនិងសុវត្ថិភាព។

## សេចក្តីប្រកាសបដិសេធរបស់ការស្ទង់មតិ

អង្គការទស្សនៈពិភពលោកបានប្រមូលមតិយោបល់របស់ប្រជាពលរដ្ឋលើគោលដៅអាទិភាពដោយប្រើទម្រង់បោះឆ្នោតយ៉ាងសាមញ្ញមួយក្រោយពេលប្រជាពលរដ្ឋត្រូវបានពន្យល់ ដោយសង្ខេបពីគោលបំណងនៃការស្ទង់មតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនីមួយៗ។ ការប្រមូលមតិយោបល់នេះត្រូវបានធ្វើឡើងដោយបុគ្គលិកអង្គការទស្សនៈពិភពលោក និងយុវជនស្ម័គ្រចិត្តនៅចន្លោះខែឧសភានិង កក្កដាឆ្នាំ២០១៦ នៅខេត្តនិងក្រុងគោលដៅរបស់អង្គការ នៅពេលអនុវត្តកម្មវិធីគម្រោង និងនៅក្នុងព្រឹត្តិការណ៍សាធារណៈផ្សេងៗ។

ការស្ទង់មតិនេះផ្អែកទៅលើការចូលរួមដោយស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋ ដូច្នេះវាមិនបានផ្តល់ជាសំណាកមួយដែលតំណាងឲ្យប្រទេសទាំងមូល នោះទេ។ ទោះជាយ៉ាងនេះក្តី ការស្ទង់មតិនេះបង្ហាញយ៉ាងទូលំទូលាយនូវការយល់ឃើញលើ SDGs របស់សាធារណៈជនជាច្រើននាក់ ដែលស្ថិត ក្នុងក្រុមអាយុផ្សេងៗគ្នា។

PO Box 479, Phnom Penh, Cambodia
facebook.com/WorldVisionCambodia
Phone +855-23-216 052
Fax +855-23-216 220
@WVCambodia
contact_cambodia@wvi.org
wvi.org/cambodia
youtube.com/wvcambodia

Copyright© September 2016 by WorldVision